# ជំពូក ៣

## ក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ

## Relevant Law and Regulation

Draft

# ជំពូកទី ៣

## គ្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ

### ៣.១ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ ១៩៩៦

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ត្រូវបានអនុម័តដោយរដ្ឋសភាជាតិ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ។ ច្បាប់នេះមានគោលដៅ :

- ការពារលើកកំពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋ ដោយធ្វើការទប់ស្កាត់ការកាត់បន្ថយ និងការត្រួតពិនិត្យការបំពុល ។
- វាយតំលៃហេតុប៉ះពាល់បរិស្ថានមុននឹងចេញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលចំពោះរាល់គំរោងដែលបានស្នើឡើង ។
- ធានាឱ្យមានការអភិរក្ស ការអភិវឌ្ឍន៍ ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ។
- លើកទឹកចិត្ត និងផ្តល់លទ្ធភាពឱ្យសាធារណជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។
- បង្ក្រាបអំពើទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន ។

ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិច្បាប់នេះ បានតម្រូវឱ្យបណ្តាក្រុមហ៊ុនទាំងអស់ត្រូវរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន (EIA) ឬ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ (ESIA) ។ ផ្អែកលើច្បាប់ នេះបានចែងនៅក្នុងមាត្រាទី៦ និង៧ នៃជំពូកទី៣ ដូចតទៅ :

- ***<u>មាត្រា៦</u>*** *: ការវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តលើគំរោង និងសកម្មភាពរបស់ឯកជន ឬ សាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតំលៃដោយក្រសួងបរិស្ថាន មុនដាក់ជូនរាជរដ្ឋាភិបាលសម្រេច ។*

  *ការវាយតំលៃនេះត្រូវ អនុវត្តផងដែរ ចំពោះសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ហើយដែលពុំទាន់បានវាយតំលៃហេតុប៉ះពាល់បរិស្ថាននៅឡើយ ។*

  *បែបបទនៃកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន ។ ប្រភេទ និងទំហំគំរោង និងសកម្មភាពដែលបានស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ទាំងឯកជន និងសាធារណៈ ដែលត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាននេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន ។*

- ***<u>មាត្រា៧</u>*** *: ចំពោះរាល់ពាក្យសុំធ្វើគំរោងវិនិយោគ និងរាល់គំរោងដែលរដ្ឋស្នើឡើង ត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (EIA) ឬ ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ (ESIA) ដូចមានចែងក្នុងមាត្រា៦ នៃច្បាប់នេះ ។ ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់លើ (IEIA) ឬ (ESIA) ទៅអង្គការមានសមត្ថកិច្ចក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។*

## ៣.២ ច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

ច្បាប់ស្តីពីការងារ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៧ ។ នាសម័យប្រជុំលើកទី ៧ និតិកាលទី១ ដែលមានដូចតទៅ :

- *__មាត្រា២២៨__ : គ្រប់គ្រឹះស្ថាន និងទីកន្លែងធ្វើការ ត្រូវរក្សាឱ្យបានស្អាតហើយបង្ហាញថា មានលក្ខខ័ណ្ឌអនាម័យ និងសភាព សុខសប្បាយជានិច្ច ឬជាទូទៅត្រូវឱ្យមានលក្ខខ័ណ្ឌការងារជាចាំបាច់សំរាប់សុខភាពរបស់កម្មករនិយោជិត ។*

  *ក្រសួងទទួលបន្ទុកវិស័យការងារ និងក្រសួងពាក់ព័ន្ធ ត្រូវរៀបចំធ្វើប្រកាសដើម្បីតាមដានត្រួតពិនិត្យការអនុវត្តន៍មាត្រានេះ សំរាប់ឱ្យបាននៅគ្រប់គ្រឹះស្ថាន ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃជំពូកនេះ ជាពិសេសដែលពាក់ព័ន្ធដល់ :*

  - *គុណភាពនៃទីកន្លែងធ្វើការ*
  - *ការបោសសំអាត*
  - *បរិក្ខារអនាម័យដែលត្រូវមានសំរាប់សេចក្តីត្រូវការរបស់បុគ្គលិក*
  - *ភេសជ្ជៈ និងអាហារ*
  - *ការស្នាក់នៅជាយថាហេតុរបស់បុគ្គលិក*
  - *ប៉ុស្តិ៍ការងារ និងការរៀបចំអាសនៈធ្វើការ*
  - *វិធានការសំរាប់ធ្វើឱ្យខ្យល់ចេញចូលបានស្រួល និងការសំអាតបរិយាកាស កន្លែងធ្វើការ*
  - *ឧបករណ៍ការពារផ្ទាល់ខ្លួន និងសំលៀកបំពាក់ការងារ*
  - *ពន្លឺ និងសំលេងក្នុងកន្លែងធ្វើការ*

- *__មាត្រា២៣០__ : គ្រប់គ្រឹះស្ថាន និងទីកន្លែងធ្វើការត្រូវរៀបចំយ៉ាងណាឱ្យមានការធានាសុវត្ថិភាពរបស់កម្មករនិយោជិត ។ គ្រឿងម៉ាស៊ីន គ្រឿងយន្ត បរិធានសំរាប់ការបញ្ជូនឧបករណ៍តូចធំ និងម៉ាស៊ីន ត្រូវដាក់និងរៀបចំក្នុងលក្ខខ័ណ្ឌប្រសើរបំផុតនៃសន្តិសុខ ។ ការចាត់ចែងការងារបច្ចេកទេសដែលប្រើប្រាស់សំភារៈ ឧបករណ៍តូចធំ ម៉ាស៊ីន ឬផលិតផលប្រើប្រាស់រួចត្រូវទុកដាក់ឱ្យបានល្អ ដើម្បីធានាសន្តិសុខរបស់កម្មករនិយោជិត ។*

  *ប្រកាសដែលមានចែងក្នុងមាត្រា ២២៩ ក៏កំណត់ផងដែរនូវវិធានការសំរាប់អនុវត្តមាត្រានេះ ពិសេសដែលពាក់ព័ន្ធដល់:*

  - *ហានិភ័យនៃការជ្រុះធ្លាក់*
  - *ការប្តូរទីតាំងនៃវត្ថុធ្ងន់ៗ*
  - *ការការពារម៉ាស៊ីន និងបរិធានដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់*
  - *វិធានការការពារដែលត្រូវចាត់ចែងឱ្យមានក្នុងករណីធ្វើការងារក្នុងកន្លែងចង្អៀត ឬស្ថានភាពការងារដាច់តែឯង*
  - *ហានិភ័យនៃការហៀរចេញវត្ថុរាវ*
  - *ការការពារអគ្គីភ័យ ។*

Draft

- **<u>មាត្រា២៤៧</u>** : ក្រសួងទទួលបន្ទុកវិស័យការងារ និងក្រសួងសុខាភិបាលត្រូវចេញប្រកាសរួមកំណត់ :

  ក- លក្ខខ័ណ្ឌរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមពេទ្យការងារ ។

  ខ- រយៈពេលអតិបរមាដែលពេទ្យការងារត្រូវធ្វើការបំរើបុគ្គលិក នៃគ្រឹះស្ថានដែលច្បាប់បានចង្អុលស្របទៅតាមចំនួនបុគ្គលិកនិងប្រភេទនៃសកម្មភាពព្រមទាំងមុខការជាចាំបាច់ ។

  គ- ពេលវេលានិងខ្លឹមសាររបាយការណ៍ដែលសហគ្រាស ឬតំណាងក្រុមអន្តរសហគ្រាសត្រូវធ្វើ អំពីការរៀបចំការប្រព្រឹត្តិទៅ និងការគ្រប់គ្រងហិរញ្ញវត្ថុនៃក្រុមពេទ្យ ។

- **<u>មាត្រា២៤៨</u>** : ត្រូវចាត់ទុកគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលកើតឡើងដោយធ្វើការ ឬក្នុងពេលធ្វើការ ទោះដោយហេតុយ៉ាងណាក៏ដោយ ហើយទោះមានកំហុសមកពីកម្មករនិយោជិត ឬគ្មានក៏ដោយ គឺគ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិតក្នុងពេលធ្វើការឱ្យនិយោជក ឬនាយកសហគ្រាស ឬធ្លាក់លើសិស្សវិជ្ជាជីវៈ មានឈ្នួលក្តី ឥតឈ្នួលក្តី កាន់មុខងារជាអ្វីនៅទីកន្លែងណាក៏ដោយ ។

  ម្យ៉ាងទៀតត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារដែរ ចំពោះគ្រោះថ្នាក់ណាដែលធ្លាក់លើកម្មករនិយោជិតក្នុងពេលដែលសាមុីខ្លួន ធ្វើដំណើរពីលំនៅស្ថានខ្លួនត្រង់ឆ្ពោះទៅទីកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ ឬដោយគ្មានវាងទៅទីកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតម្រូវឱ្យទៅ ។

  ជម្ងឺបណ្តាលមកពីវិជ្ជាជីវៈទាំងអស់ ដូចមានបញ្ជាក់ក្នុងច្បាប់ ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ ហើយទទួលការជួសជុលដូចគ្នាដែរ ។

- **<u>មាត្រា២៤៩</u>** : នាយកសហគ្រាស ត្រូវទទួលខុសត្រូវលើគ្រោះថ្នាក់ការងារទាំងអស់ ដូចមានរៀបរាប់ក្នុងមាត្រាខាងលើនេះ ទោះបីលក្ខន្តិកៈផ្ទាល់ខ្លួនរបស់កម្មករនិយោជិតម្នាក់ៗនោះ មានលក្ខណៈយ៉ាងណាក៏ដោយ ។

  ការទទួលខុសត្រូវដូចគ្នានេះ ត្រូវអនុវត្តលើ :

  - អ្នកគ្រប់គ្រងគ្រឹះស្ថានព្យាបាលឯកជន ចំពោះតែបុគ្គលិកដែលអ្នកគ្រប់គ្រងនេះប្រើ
  - ជនដែលមានវិជ្ជាជីវៈសេរី ចំពោះតែគ្រោះថ្នាក់លើកម្មករនិយោជិតរបស់ជននោះ
  - សហគ្រាសសិប្បកម្ម ចំពោះកម្មករនិយោជិតក្រៅពីប្រពន្ធកូនរបស់សិប្បករ
  - ម្ចាស់ផ្ទះ ចំពោះតែគ្រោះថ្នាក់លើអ្នកបំរើក្នុងផ្ទះរបស់ខ្លួន
  - សហគ្រាសកសិកម្ម ចំពោះគ្រោះថ្នាក់នៃកម្មករនិយោជិតក្នុងសហគ្រាសនោះ ។

  ក្រៅពីប្រភេទដូចមានចែងជាក់លាក់ក្នុងកថាខ័ណ្ឌខាងដើមនេះ ជនណាដែលទទួលកម្មករនិយោជិតឱ្យប្រកបការណាមួយជាប្រាកដ និងម្តងម្កាលឱ្យខ្លួន ត្រូវតែជួសជុលគ្រោះថ្នាក់ផ្សេងៗដែលកម្មករនិយោជិតត្រូវរងគ្រោះ ក្នុងឱកាសដែលបំពេញការងារនោះ ។

- **<u>មាត្រា២៥០</u>** : នាយកសហគ្រាសគ្រប់រូបត្រូវចាត់ ឬប្រើឱ្យគេចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីបង្ការគ្រោះថ្នាក់ការងារផ្សេងៗ ។

Draft

## ៣.៣ ច្បាប់ភូមិបាល ឆ្នាំ ២០០១

ច្បាប់ភូមិបាលនេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ២ ។

- **មាត្រា ១:** ច្បាប់នេះមានគោលដៅកំណត់អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាការពារសិទ្ធិនៃ កម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀត លើអចលនវត្ថុស្របតាមបទប្បញ្ញត្តិ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា ។
- **មាត្រា ៣:** ជនគ្រប់រូបត្រូវគោរពទ្រព្យសម្បត្តិរបស់រដ្ឋ និងកម្មសិទ្ធិឯកជនស្របច្បាប់លើអចលនវត្ថុ ។ ការគ្រប់គ្រងផ្នែករដ្ឋបាលសុរិយោដី លើអចលនវត្ថុដែលជាទ្រព្យសម្បតិរបស់រដ្ឋ និងការចេញប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ។ បទបញ្ញា និងនិតិវិធីនៃការគ្រប់គ្រងអចលនវត្ថុដែលជាទ្រព្យសម្បតិរបស់រដ្ឋ នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។
- **មាត្រា ៥:** គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះ មិនមែនដើម្បីប្រយោជន៍សាធារណៈ ។ ការដកហូតត្រូវធ្វើទៅតាមទម្រង់ និងនិតិវិធីបញ្ញត្តិដោយច្បាប់ និងបទបញ្ញាបន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ ។
- **មាត្រា ៧:** របបកម្មសិទ្ធិលើអចលនវត្ថុមុនឆ្នាំ ១៩៧៩ មិនត្រូវបានទទួលស្គាល់ ។
- **មាត្រា ៣០:** បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ (ប្រាំ) ឆ្នាំយ៉ាងតិច គិតមកដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់នេះលើអចលនវត្ថុ ដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុងការកាន់កាប់ជាឯកជន មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ ។ ក្នុងករណីមានការជំទាស់ដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិស្ថាពរនេះ អ្នកតវ៉ាត្រូវយកភស្តុតាងមកបញ្ជាក់ថា ខ្លួនឯងផ្ទាល់បានបំពេញលក្ខខ័ណ្ឌនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ (ប្រាំ) ឆ្នាំ នៅលើអចលនវត្ថុដែលមានជំទាស់ ឬយកភស្តុតាងដែលថា ខ្លួនបានទិញអចលនវត្ថុ នោះពីភោគីដើម ឬពីសិទ្ធិវន្តស្របច្បាប់ ឬអ្នកទទួលផ្ទេរកម្មសិទ្ធិ ឬពីសន្តតិជនរបស់ខ្លួន ។
- **មាត្រា ៤២:** បុគ្គលទាំងឡាយណាដែលមិនបានចុះបញ្ជីភោគៈស្របច្បាប់របស់ខ្លួន ដោយហេតុមិនបានដឹងឬដោយធ្វេសប្រហែស អ្នកនោះនៅតែមានសិទ្ធិត្រូវបានការពារតាមអំណាចនៃមាត្រា ២៩ មាត្រា ៣០ និងមាត្រា ៣១ នៃច្បាប់នេះ ។
- **មាត្រា ៤៣:** ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចជាកម្មវត្ថុនៃលទ្ធកម្មកម្មសិទ្ធិបានឡើយ ទោះក្នុងករណីណាក៏ដោយ ។ ស្ថានភាពនៃអ្នកកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនៅតែមិនទៀងទាត់ និងខុសច្បាប់ដដែល ប្រសិនជាស្ថានភាពនោះមិនកើតចេញពីការអនុញ្ញាតតាមបែបផែនដែលបានកំណត់ដោយច្បាប់ទេនោះ ។ បុគ្គលកាន់កាប់ខុសច្បាប់ត្រូវបង្ខំឱ្យចាក់ចេញជាបន្ទាន់ ហើយត្រូវទទួលទណ្ឌកម្មដែលបានកំណត់ក្នុងមាត្រា ២៥៩ នៃច្បាប់នេះ ។ បុគ្គលកាន់កាប់ខុសច្បាប់គ្មានសិទ្ធិទាមទារសំណងសំរាប់ចំណាយលើការងារ និង ការកែលំអរដែលខ្លួនបានធ្វើនៅលើអចលនវត្ថុនោះឡើយ ។

Draft

- **មាត្រា ៥៨:** សម្បទានដី អាចធ្វើឡើងបានតែនៅលើដីដែលជាចំណែកនៃទ្រព្យសម្បត្តិឯកជនរបស់ រដ្ឋ ។ សម្បទានដីមិនអាចប៉ះពាល់ផ្លូវគមនាគមន៍ ដីចំណីផ្លូវ និងដីចាំបាច់សំរាប់ថែទាំ ក៏ដូចជាផ្លូវទឹក ត្រពាំង បឹង និងដែនទឹកបំរុងដែលមានប្រយោជន៍ដល់ការរស់នៅរបស់ប្រជាពលរដ្ឋឡើយ ។

- **មាត្រា ៥៩:** សម្បទានដីអាចមានទំហំច្រើនបំផុតត្រឹមតែ ១០.០០០ (មួយម៉ឺនហិកតា) ហិកតា ។ សម្បទានដីដែលសម្រេចហើយ ហើយមានទំហំលើសពីទំហំកំណត់ខាងលើជាកម្មវត្ថុនៃការកាត់បន្ថយ ។ ប៉ុន្តែប្រសិនបើការកាត់បន្ថយនេះមានឥទ្ធិពលធ្វើឱ្យខូចប្រយោជន៍អាជីវកម្មដែលកំពុងមានដំណើរការ សម្បទានិកអាចនឹងទទួលបានការលើកលែងជាពិសេស ។ និតិវិធីនៃការកាត់បន្ថយ និងការលើកលែង ជាពិសេសត្រូវកំណត់ដោយអនុក្រឹត្យ ។ ត្រូវបានហាមឃាត់ការចេញលិខិតសម្បទានដីច្រើនកន្លែងឱ្យបុគ្គលតែម្នាក់ ឬ ឱ្យនិតិបុគ្គលច្រើនតែគ្រប់គ្រងដោយរូបវន្តបុគ្គល ឬនិតិបុគ្គលដដែលៗ ដែលមានទំហំសរុបធំជាងទំហំដែលបានកំណត់នៅវាក្យខ័ណ្ឌខាងលើ ។

## ៣.៤ ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ ២០០២

ច្បាប់ស្តីពីព្រៃឈើ ត្រូវបានអនុម័តដោយរដ្ឋសភាជាតិ និងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម /០៨០២/០១៦/៣១ សីហា ២០០២ , អនុម័តនៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២ ។ ច្បាប់នេះមានមាត្រាចំនួនខាងក្រោម ដែលពាក់ព័ន្ធ នឹងគំរោង :

- **មាត្រា១** : ច្បាប់នេះកំណត់អំពីក្របខ័ណ្ឌនៃការគ្រប់គ្រង ការប្រមូលផល ការប្រើប្រាស់ ការធ្វើអាជីវកម្ម ការអភិវឌ្ឍន៍ និង ការអភិរក្សព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
  គោលបំណងនៃច្បាប់នេះ គឺធានានូវការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និង បរិស្ថានរួមទាំងការអភិរក្សជីវៈចំរុះ និងមរតកវប្បធម៌ ។
- **មាត្រា២** : ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់ព្រៃឈើទាំងអស់ ទោះជាប្រភេទព្រៃនោះកើតឡើងដោយធម្មជាតិក្តី ឬ ដោយដាំក្តី ។ រដ្ឋធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីនូវផលអនុផលព្រៃឈើរបស់សមាគមន៍មូលដ្ឋានក្រោមបទបញ្ញត្តិនៃច្បាប់នេះ ឬ ច្បាប់ពាក់ពន្ធ័ផ្សេងទៀត ។
- **មាត្រា៣** : ការគ្រប់គ្រងព្រៃឈើត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅ នៃក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ការគ្រប់គ្រងព្រៃលិចទឹក ស្ថិតនៅក្រោមច្បាប់មួយដោយឡែក ។
  រដ្ឋផ្តល់សិទ្ធិគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថាន ក្រោមបទបញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើត និង ការកំណត់តំបន់ការពារ ធម្មជាតិ ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ និង លិខិតបទដ្ឋានច្បាប់ផ្សេងទៀត ។
  ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តន៍ច្បាប់ ចំពោះរាល់បទល្មើសព្រៃឈើដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិក្រោមការសម្របសម្រួលជាមួយក្រសួងបរិស្ថាន ស្របតាមបទបញ្ញត្តិ ដូចមានចែងក្នុងជំពូកទី ១៤ នៃច្បាប់នេះ ។

សកម្មភាពនេះនឹងមិនធ្វើឱ្យប៉ះពាល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិឡើយ ។

- **មាត្រា៩** : ក្នុងការអនុវត្តន៍ច្បាប់នេះ រាល់ការសម្រេចរបស់រាជរដ្ឋាភិបាលដែលមានសក្តានុភាពចំពោះផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជារដ្ឋទូទៅ លើជីវភាពសមាគមន៍មូលដ្ឋាន និង លើធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការចូលរួមជាសាធារណៈ ។

សកម្មភាពចំបង១ ពាក់ពន្ធ័ទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ ដែលអាចបណ្តាលឱ្យមានផលប៉ះពាល់អាក្រក់ដល់សង្គម និង បរិស្ថាន ចាំបាច់ត្រូវមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និង ផលប៉ះពាល់សង្គម ដោយផ្អែកតាមក្រុមបច្ចេកទេស គ្រប់គ្រងព្រៃឈើកម្ពុជា និង ស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ ។ ឯកសារនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និង ផលប៉ះពាល់សង្គម ត្រូវផ្តល់ជូនសំរាប់ការចូលរួមផ្តល់មតិជាសាធារណៈបាន ។

រាល់ការសម្រេចចុងក្រោយលើរាល់សកម្មភាពចំបង១ ពាក់ពន្ធ័ទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើរាជរដ្ឋាភិបាលត្រូវពិចារណាលើអនុសាសន៍ ចុងក្រោយនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ។

ការសម្រេចចុងក្រោយណាមួយក្រោមមាត្រានេះ រាជរដ្ឋាភិបាលអាចធ្វើការជូនដំណឹងជាសាធារណៈ ។

- **មាត្រា១០** : សម្បត្តិព្រៃឈើអចិន្ត្រៃយ៍រួមមាន:

  ១- ព្រៃបំរុងទុកអចិន្ត្រៃយ៍ ។

  ២- ព្រៃឯកជន ។

ព្រៃបំរុងទុកអចិន្ត្រៃយ៍រួមមានបីប្រភេទ:

  ១- ព្រៃផ្តល់ផលត្រូវបានរក្សាទុកសំរាប់ផលិតកម្មផល អនុផលព្រៃឈើប្រកបដោយនិរន្តរភាព ដែលក្នុងនោះមុខងារការពារត្រូវចាត់ទុកជាអាទិភាពបន្ទាប់ ។ ព្រៃផ្តល់ផលមានជាអាទិ៍ :

  - ព្រៃសម្បទាន
  - ព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន
  - ព្រៃឈើត្រូវស្តារឡើងវិញ
  - ផ្ទៃដីព្រៃបំរុងទុកសំរាប់ដាំដើមឈើឡើងវិញ ឬ ចំការព្រៃឈើ
  - ផ្ទៃដីព្រៃបំរុងទុកសំរាប់បន្តពូជព្រៃឈើ
  - ផ្ទៃដីព្រៃរិចរឹល
  - ព្រៃសហគមន៍ក្រោមកិច្ចព្រមព្រៀង ។

  ២- ព្រៃការពារត្រូវបានរក្សាទុកជាចំបង ដើម្បីការពារប្រព័ន្ធមជ្ឈដ្ឋាន និងធនធានធម្មជាតិ ។ ព្រៃការពារមានជាអាទិ៍:

  - ព្រៃបំរុងទុកសំរាប់ប្រព័ន្ធមជ្ឈដ្ឋានពិសេស
  - ព្រៃសំរាប់សិក្សាស្រាវជ្រាវ

- ព្រៃនិយតកម្មប្រភពទឹក
- ព្រៃការពារទីជំរាល
- ព្រៃលំហែកំសាន្ត
- សួនភូគគាម
- ព្រៃជំនឿសាសនា ។

ព្រៃការពារនេះអាចអនុញ្ញាតិឱ្យប្រមូលផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណី ដែលមានផលប៉ះពាល់ទាប ដោយសហគមន៍មូលដ្ឋាន ។

៣- ផ្ទៃដីព្រៃសំរាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍន៏ផ្សេងទៀត ជាដីទំនេរដុះរុក្ខជាតិ ព្រៃបន្ទាប់បន្សំ ដែលមិនទាន់ស្ថិតនៅក្នុងការប្រើប្រាស់របស់វិស័យណាមួយនៅឡើយ ត្រូវតែដាក់ឱ្យស្ថិតនៅក្នុងចំណាត់ថ្នាក់នៃព្រៃបំរុងទុកអចិន្ត្រៃយ៏រហូតដល់មានការសម្រេចឱ្យប្រើប្រាស់ និងអភិវឌ្ឍន៏សំរាប់គោលបំណងផ្សេងទៀតដោយរាជរដ្ឋាភិបាល ។

ព្រៃឯកជនត្រូវថែរក្សាដោយម្ចាស់កម្មសិទ្ធិ និងមានសិទ្ធិទទួលផលប្រយោជន៏ក្នុងការអភិវឌ្ឍន៏ និងប្រមូលផលប្រើប្រាស់ លក់ចែកចាយ ផលិតផលរបស់ខ្លួនដោយផ្ទាល់ ។

- **មាត្រា១២** : រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិអំណាចរំសាយចំណាត់ថ្នាក់ព្រៃឈើណាមួយពីព្រៃបំរុងទុកអចិន្ត្រៃយ៏ ។

ការសម្រេចបែបនេះត្រូវស្ថិតនៅក្នុងផលប្រយោជន៏សាធារណៈ និង មានសង្គតិភាពជាមួយគោលនយោបាយ វិស័យព្រៃឈើជាតិ ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ និងទិន្នន័យបច្ចេកទេសសង្គម សេដ្ឋកិច្ច ដែលផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ស្របតាមបទបញ្ញត្តិ ដូចមានចែងក្នុងច្បាប់នេះ ការរំសាយចំណាត់ថ្នាក់ណាមួយនៃព្រៃ បំរុងទុកអចិន្ត្រៃយ៏ សំរាប់គោលបំណងមិនមែនព្រៃឈើ ត្រូវពិចារណាលើអាទិភាពដូចខាងក្រោមៈ

១- ផ្ទៃដីព្រៃសំរាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍន៏ផ្សេងទៀត ។

២- ដីព្រៃបំរុងទុកអចិន្ត្រៃយ៏ផ្សេងទៀត ដែលតម្រូវការបច្ចុប្បន្នខ្ពស់ជាងតម្រូវការដែលកំណត់កន្លងមក ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចស្នើសុំរាជរដ្ឋាភិបាលកំណត់រកផ្ទៃដីព្រៃទំនេរផ្សេងទៀត ដើម្បីជំនួយផ្ទៃដី ព្រៃបំរុងទុកអចិន្ត្រៃយ៏ ដែលបានរំសាយក្នុងគោលបំណងការពារ និង ដាំព្រៃឡើងវិញ ដើម្បីរក្សាគំរបជាអចិន្ត្រៃយ៏ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចស្នើសុំរាជរដ្ឋាភិបាលសម្រេចធ្វើការផ្លាស់ប្តូរចំណាត់ថ្នាក់ព្រៃណាមួយនៅក្នុង ដែនព្រៃបំរុងទុកអចិន្ត្រៃយ៏ ដោយផ្អែកលើទិន្នន័យសិក្សាថ្មី និងមុខងាររបស់ដីព្រៃនោះ ។

រាល់សម្រេចរំសាយចំណាត់ថ្នាក់ព្រៃឈើ ដូចមានចែងក្នុងកថាខ័ណ្ឌទី១ និងការផ្លាស់ប្តូរចំណាត់ថ្នាក់ព្រៃឈើដូចមានចែងក្នុងកថាខ័ណ្ឌទី៣ នៃមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យ ។

- **មាត្រា៣៧** : សហគមន៏មូលដ្ឋាន ដែលប្រកបរបរចំការពនេចរមានលក្ខណៈប្រពៃណី អាចអនុវត្តលើដីកម្មសិទ្ធិ សហគមន៏ជនជាតិភាគតិច ដែលបានចុះបញ្ជិការួចហើយជាមួយរដ្ឋ ។ ផ្អែករដ្ឋបាលព្រៃឈើនៃមូលដ្ឋាននេះ

Draft

ត្រូវផ្តល់ការអនុញ្ញាតិការគ្រប់គ្រង និងការត្រួតពិនិត្យនៃសកម្មភាពនេះ ដែលជាផ្នែកមួយនៃផែនការគ្រប់គ្រងព្រៃសហគមន៍នោះ ។ ការអនុវត្តន៍ចំការពនេចរ ត្រូវហាមឃាត់ចំពោះព្រៃធម្មជាតិមិនទាន់ ប៉ះពាល់ក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ ។ ដីព្រៃឈើដែលរៀបចំបំរុងសំរាប់ចំការពនេចរ ត្រូវកំណត់ដោយអនុក្រឹត្យ ។

- **មាត្រា៣៩** : គ្មានរូបវន្តបុគ្គលណាមួយមានសិទ្ធិផ្តល់ការអនុញ្ញាតិ ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី ឱ្យកាប់ដើមឈើ ឬ ធ្វើសកម្មភាពគ្រប់យ៉ាង ដើម្បីប្រមូលផល អនុផលព្រៃឈើ ឬ កាន់កាប់ដីក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ ផ្ទុយនឹងបទបញ្ញត្តិនៃច្បាប់នេះឡើយ ។

- **មាត្រា៤០** : ចំពោះសហគមន៍មូលដ្ឋានរស់នៅក្នុង ឬ ក្បែរដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ រដ្ឋត្រូវទទួលស្គាល់ និងធានា សិទ្ធិប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍មូលដ្ឋាន នោះសំរាប់គោលបំណងទំនៀមទំលាប់ ជំនឿ សាសនា និងការរស់នៅ ដូចមានចែងក្នុងមាត្រានេះ ។

សិទ្ធិប្រើប្រាស់ជាប្រពៃណីលើផល អនុផលព្រៃឈើដោយសហគមន៍មូលដ្ឋាន មិនតម្រូវឱ្យមានលិខិតអនុញ្ញាតិប្រមូលផលឡើយ ។ សិទ្ធិប្រើប្រាស់ជាប្រពៃណីក្រោមមាត្រានេះរួមមាន :

១- ការរើសប្រមូលឈើងាប់ ការបេះផ្លែឈើព្រៃ ការរុករកឃ្មុំ ការចោះយកជ័រ និង រុករកអនុផលព្រៃឈើដទៃទៀតទាំងអស់ ។

២- ការប្រើប្រាស់ឈើមកសង់លំនៅដ្ឋាន ក្រោលសត្វ របង និង សំរាប់ធ្វើឧបករណ៍កសិកម្ម ។

៣- ការច្រូតយកស្មៅ ឬ លែងសត្វពាហនៈឱ្យស៊ីស្មៅក្នុងព្រៃ ។

៤- ការប្រើប្រាស់ផល អនុផលព្រៃឈើផ្សេងទៀតស្របតាមការប្រើប្រាស់ជាប្រពៃណី ជាលក្ខណៈគ្រួសារ ។

៥- សិទ្ធិដោះដូរ ឬ លក់អនុផលព្រៃឈើដោយពុំចាំបាច់មានលិខិតអនុញ្ញាតប្រសិនបើការលក់ដូរនេះមិនគំរាមកំហែង ដល់និរន្តរភាពព្រៃឈើ ។ អតិថិជន ឬ ភាគីទីបីណាមួយដែលបានប្រមូលទិញអនុផលព្រៃឈើទាំងនោះពីសហគមន៍មូលដ្ឋាន ក្នុងគោលដៅពាណិជ្ជកម្មស្របតាមបទបញ្ញត្តិនៃច្បាប់នេះអាចធ្វើការដឹកជញ្ជូនទៅកាន់បានដោយតម្រូវឱ្យមានលិខិតអនុញ្ញាតិដឹកជញ្ជូនក្រោយពេលបានបង់ថ្លៃសួយសារ និងបុព្វលាភលើអនុផលព្រៃឈើទាំងនោះរួច ។

សហគមន៍មូលដ្ឋានមិនអាចផ្ទេរសិទ្ធិប្រើប្រាស់ជាប្រពៃណីឱ្យទៅភាគីទីបីបានឡើយ ទោះបីជាមានកិច្ចព្រមព្រៀងទៅវិញមកក្តី ឬស្ថិតក្រោមកិច្ចសន្យាក្តី ។ សិទ្ធិប្រើប្រាស់ជាប្រពៃណីត្រូវ :

១- ស្របតាមលំនឹងធម្មជាតិ មាននិរន្តរភាពចំពោះធនធានព្រៃឈើ និងគោរពសិទ្ធិអ្នកដទៃ ។

២- ស្របតាមការអនុញ្ញាតិ និង ការហាមឃាត់ ដែលកំណត់ដោយបទបញ្ញត្តិនៃច្បាប់នេះ ។

- **មាត្រា៤១** : រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទមានសិទ្ធិប្រគល់ផ្នែកណាមួយនៃព្រៃបំរុងទុកអចិន្ត្រៃយ៍ឱ្យទៅសហគមន៍ដែលរស់នៅក្នុង ឬ ជិតតំបន់ព្រៃឈើក្រោមរូបភាពជាព្រៃសហគមន៍ ។

- **មាត្រា៤២** : ខ័ណ្ឌរដ្ឋបាលព្រៃឈើ តាមរយៈដំណើរការពិគ្រោះយោបល់ជាមួយសមត្ថកិច្ចពាក់ព័ន្ធដទៃទៀតមានភារកិច្ចសិក្សារៀបចំព្រៃបំរុងទុកអចិន្ត្រៃយ៍ ដើម្បីបង្កើតជាព្រៃសហគមន៍ ដោយកំណត់ព្រំប្រទល់ច្បាស់លាស់ និង

Draft

មានទំហំសមស្រប ផ្អែកតាមលទ្ធភាពធនធានព្រៃឈើ និង តម្រូវការប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍ ។ នាយខ័ណ្ឌរដ្ឋបាលព្រៃឈើមានសិទ្ធិសម្រេចចុះកិច្ចព្រមព្រៀងព្រៃសហគមន៍

ជាមួយសហគមន៍មូលដ្ឋានណាមួយដែលរស់នៅក្នុង ឬក្បែរដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ ។ កិច្ចព្រមព្រៀងនេះត្រូវមានសុពលភាពមិនលើសពីរយៈពេលដប់ប្រាំ (១៥) ឆ្នាំ តែអាចពន្យាលបាន ដោយផ្អែកលើរបាយការណ៍ពិនិត្យ និងវាយតំលៃឡើងវិញរបស់ថ្នាក់ផ្អែករដ្ឋបាលព្រៃឈើ ។

- **មាត្រា៩៥** : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលស្គាល់ព្រៃពាក់ព័ន្ធជំនឿសាសនារបស់សហគមន៍មូលដ្ឋានដែលរស់នៅក្នុង ឬ ក្បែរព្រៃនោះទុកជាព្រៃការពារសំរាប់គោលបំណងសាសនា វប្បធម៌ ឬការអភិរក្ស ។ ដើមឈើជំនឿសាសនាអាចត្រូវបានសំគាល់ជាពិសេស មិនអនុញ្ញាតិឱ្យកាប់រំលំ និងត្រូវកំណត់ក្នុងផែនការការគ្រប់គ្រងព្រៃសហគមន៍ ។

- **មាត្រា៩៦** : បុគ្គលដែលបានដាំដើមឈើលើដីកម្មសិទ្ធិឯកជនផ្ទាល់ ឬ លើដីព្រៃរបស់រដ្ឋ ដែលបានប្រគល់សិទ្ធិប្រើប្រាស់ មានសិទ្ធិថែរក្សា អភិវឌ្ឍន៍ប្រើប្រាស់ លក់ និងចែកចាយផលិតផលរបស់ខ្លួនបាន ។ វិធានស្តីពីព្រៃឯកជនត្រូវកំណត់ដោយ ប្រកាសរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីជំរុញលើកទឹកចិត្តដល់បុគ្គលក្នុងការដាំដុះ និងថែទាំចំការព្រៃឈើ ។

- **មាត្រា៩៧** : រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចបន្ថយ ឬ មិនយកថ្លៃសួយសារ និង បុព្វលាភលើផលអនុផលព្រៃឈើដែលប្រមូលពីព្រៃឈើរដ្ឋ សំរាប់គោលបំណងវិទ្យាសាស្ត្រ ឬដើម្បីបង្កើនការលើកទឹកចិត្តសេដ្ឋកិច្ច ចំពោះការប្រើប្រាស់អស់លទ្ធភាពលើផលិតផល ។

រដ្ឋមិនយកថ្លៃសួយសារ និង បុព្វលាភពីសហគមន៍មូលដ្ឋានលើផល អនុផលព្រៃឈើដែលប្រមូលដោយសហគមន៍មូលដ្ឋានសំរាប់សិទ្ធិប្រើប្រាស់ជាប្រពៃណី ឬប្រមូលពីព្រៃសហគមន៍ក្រោមកិច្ចព្រមព្រៀងព្រៃសហគមន៍ឡើយ ។

- **មាត្រា៩៨** : ទោះជាមានលិខិតអនុញ្ញាតិស្របតាមបទបញ្ញត្តិនៃច្បាប់នេះក៏ដោយ ក៏ការកាប់ដើមឈើការប្រមូល ឬ ការដឹកជញ្ជូនផល អនុផលព្រៃឈើក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ ត្រូវហាមឃាត់ចាប់ពីម៉ោងប្រាំបី (៨) យប់ ដល់ម៉ោង ប្រាំ (៥) ភ្លឺ ។

- **មាត្រា៩៩** : បុគ្គលណាដែលបានប្រព្រឹត្តិបទល្មើសព្រៃឈើ ធ្វើឱ្យប៉ះពាល់ខូតខាតដល់មជ្ឈដ្ឋានព្រៃឈើ ត្រូវចេញថ្លៃស្មារ ឬជួសជុលការខូចខាត មានលក្ខខ័ណ្ឌដូចដើមឡើងវិញ ។

- **មាត្រា១០០** : សកម្មភាពទាំងឡាយណាដែលធ្វើឡើងដោយមន្ត្រីអាជ្ញាធរដែនដី មន្ត្រីនគរបាល មន្ត្រីនៃកងយោធពលខេមរៈភូមិន្ទ ឬមន្ត្រីអាជ្ញាធរផ្សេងទៀត ដើម្បីធ្វើអន្តគមន៍ ផ្តល់ការអនុញ្ញាតិដោយផ្ទាល់ ឬ ដោយប្រយោល ជួយដល់អាជីវកម្មព្រៃឈើ និង ធ្វើសកម្មភាពគ្រប់យ៉ាង ផ្ទុយនឹងបទបញ្ញត្តិនៃច្បាប់នេះ ឬ ធ្វើការគំរាមកំហែងដល់មន្ត្រីរដ្ឋបាលព្រៃឈើ ឬ រាំងស្ទះដល់ការបំពេញភារកិច្ច និងកិច្ចប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើ ត្រូវចាត់ទុកជាបទល្មើស ដែលត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយ (១) ឆ្នាំ ទៅប្រាំ (៥) ឆ្នាំ និង ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ដប់លាន (១០. ០០០.០០០) រៀល ។

Draft

- <u>*មាត្រា១០១*</u> *: ចំពោះសកម្មភាពដូចខាងក្រោម ដែលប្រព្រឹត្តិឡើងដោយមន្ត្រីរដ្ឋបាលព្រៃឈើត្រូវចាត់ទុកជាបទល្មើស និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី (១) ឆ្នាំ ទៅប្រាំ (៥) ឆ្នាំ និង ត្រូវផ្តន្ទាទោសពិន័យ ជាប្រាក់ចំនួនពីដប់លាន (១០.០០០.០០០) រៀល ទៅមួយរយលាន (១០០.០០០.០០០) រៀល ។*

  *១- ផ្តល់ការអនុញ្ញាតិណាមួយដែលផ្ទុយ និងបទបញ្ញតិនៃច្បាប់នេះ ។*

  *២- ចូលរួមទាំងស្រុង ឬ ដោយផ្នែក និងដោយផ្ទាល់ក្នុងសកម្មភាពណាមួយនៃអាជីវកម្មព្រៃឈើដែលផ្ទុយ នឹងបទបញ្ញត្តិនៃច្បាប់នេះ ។*

  *៣- អនុគ្រោះចំពោះបទល្មើសព្រៃឈើណាមួយ ។*

  *៤- ប្រកបរបរអាជីវកម្មណាមួយពាក់ព័ន្ធ នឹងវិស័យព្រៃឈើ ទោះធ្វើជាម្ចាស់ទាំងស្រុងក្តី ជាម្ចាស់ភាគហ៊ុនក្តី ឬ ធ្វើជានិយោជិក ឬអ្នកធានាឱ្យអ្នកដទៃក្តី ក្នុងអំឡុងពេលកំពុងកាន់តំណែង ឬក្នុងអំឡុងពេលមួយ (១) ឆ្នាំ ក្រោយពីការឈប់កាន់តំណែងដោយប្រការណាក៏ដោយ ។*

  *៥- មិនបានរាយការណ៍ ឬ មិនបានដាក់ពាក្យបណ្តឹងចំពោះបទល្មើសព្រៃឈើថ្នាក់ទី ១ ដែលបានកើតក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួនទាន់ពេលវេលា ។*

  *៦- ធ្វេសប្រហែសដោយចេតនាក្នុងការបំពេញភារកិច្ច ឬផ្តល់ព័ត៌មាននូវរបាយការណ៍ក្លែងបន្លំជាលាយលក្ខណ៍អក្សរ ដែលជាមូលហេតុបង្កឱ្យកើតមានបទល្មើសព្រៃឈើថ្នាក់ទី១ ។*

## ៣.៥ ច្បាប់ជលផល ឆ្នាំ ២០០៦

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ និតិកាលទី ៣ ។

*មាត្រា ១ : ច្បាប់នេះមានគោលបំណងធានានូវការគ្រប់គ្រងជលផល និងធនធានជលផល ជំរុញកិច្ចអភិវឌ្ឍន៍វារីវប្បកម្ម ផលិតកម្ម និងការកែច្នៃលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងសហគមន៍មូលដ្ឋាន ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវចម្រុះផង ទាំងមរតកវប្បធម៌ធម្មជាតិផង ប្រកបដោយនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។*

*មាត្រា ២ : ច្បាប់នេះមានវិសាលភាពអនុវត្តលើជលផលទាំងអស់ ទាំងប្រភេទជលផលដែលកើតឡើងដោយធម្មជាតិ ទាំងជលផលកែច្នៃ និងទាំងវារីវប្បកម្ម ។*

*រដ្ឋធានាសិទ្ធប្រើប្រាស់ធនធានជលផលជាប្រពៃណីរបស់សហគមន៍មូលដ្ឋានក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ឬច្បាប់ពាក់ព័ន្ធផ្សេងទៀត ។*

*មាត្រា ៣ : ការគ្រប់គ្រងធនធានជលផល ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។*

*ការគ្រប់គ្រងព្រៃលិចទឹក និងព្រៃកោងកាង ដែលពាក់ព័ន្ធនឹងវដ្តជីវិតនៃធនធានជលផលត្រូវស្ថិតនៅក្រោមវិសាលភាពនៃច្បាប់នេះ ។*

Draft

រដ្ឋផ្តល់សិទ្ធគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថានក្រោមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងលិខិតបទដ្ឋានគតិយិត្តិផ្សេងទៀត ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធសហការធ្វើសកម្មភាពពង្រឹងការអនុវត្តច្បាប់ចំពោះ រាល់បទល្មើសជលផល ដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិ ក្រោមការសម្របសម្រួលជាមួយក្រសួងបរិស្ថានស្របតាមបទបប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី១៤ នៃច្បាប់នេះ ។ សកម្មភាពនេះ នឹងមិនធ្វើឱ្យប៉ះពាល់ដល់ដែនសមត្ថភាពគ្រប់គ្រងរបស់ក្រសួងបរិស្ថានដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ ។

**មាត្រា ៩ :** ធនធានជលផល មានសេរីរាង្គទឹកសាប និងសមុទ្រ ជាសត្វ និងរុក្ខជាតិ មានជីវិត ឬគ្មានជីវិត ជាអាទី មច្ឆជាតិ សិប្បីសត្វ ថលជលិកសត្វ បាណកសត្វ ឧរង្គសត្វ ថនិកសត្វ សត្វឥតឆ្អឹងកងផ្សេងទៀត ដែលបង្កកំណើតនៅក្នុងទឹក ប្លង់តុង សារាយ ស្មៅសមុទ្រ ផ្កាថ្ម ព្រៃលិចទឹកព្រម ទាំងព្រៃកោងកាងជាដើម ។

**មាត្រា ២២ :** ហាមឃាត់ ការចាក់ចោល ការបោះចោល ការបង្ហូរ ការបាច ពង្រាយទៅក្នុងដែននេសាទនូវកាកសំណល់រឹង ឬរាវ ឬសារធាតុពុល ដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញា ឬសន្ធិសញ្ញាអន្តរជាតិស្តីពី ការបំពុលបរិស្ថាន ឬការប្រព្រឹត្តសកម្មភាពដែលធ្វើឱ្យពុល ឬការបង្កគ្រោះថ្នាក់ដល់វារីសត្វ និងវារីរុក្ខជាតិ ។

**មាត្រា ២៥ :** ការធ្វើទំនប់កាត់ ឬការលុបទន្លេ ស្ទឹង ព្រែក អូរ បឹង ប្រឡាយ អាងទឹក និងអាងធម្មជាតិ ឬការជីកប្រឡាយរណ្តៅ និងស្រះទ្រង់ទ្រាយធំ ឬការសាងសង់សំណង់ថ្មីនានា ឬ ការបូមទឹកដែលអាចបង្កមហន្តរាយដល់ធនធានជលផលនៅក្នុងដែននេសាទ ត្រូវមានការសិក្សាវាយតម្លៃពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ៣.៦ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា_ ឆ្នាំ ២០០៧

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ និតិកាលទី ៣ ។

- **មាត្រា ១ :** ច្បាប់នេះមានគោលដៅជំរុញឱ្យមានការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធិភាព និង និរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសម្រេចបាននូវការងារអភិវឌ្ឍសេដ្ឋកិច្ចសង្គមនិងសុខមាលភាពរបស់ ប្រជាពលរដ្ឋ ។ ច្បាប់នេះកំណត់ :
  - សិទ្ធិ និងកាតព្វកិច្ចនៃអ្នកប្រើប្រាស់ទឹក
  - គោលការណ៍គ្រឹះសំខាន់ៗ សំរាប់ការគ្រប់គ្រងធនធានទឹក
  - ការចូលរួមរបស់សហគមន៍អ្នកប្រើប្រាស់ទឹក ក្នុងការអភិវឌ្ឍន៍ធនធានទឹកប្រកបដោយនិរន្តរភាព ។
- **មាត្រា ២ :** ក្នុងច្បាប់នេះ ពាក្យបច្ចេកទេសមួយចំនួនមានន័យថា :
  - ទឹក គឺទឹកលើដី ទឹកក្រោមដី និងទឹកក្នុងអាកាស ។
  - ធនធានទឹក គឺសមុទ្រ ទន្លេ ស្ទឹង ព្រែក ជ្រោះ ជ្រលងដងអូរ បឹងបួ ត្រពាំង ថ្លុក អាងទឹក ។

- ទឹកក្រោមដី គឺទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូច ធំ និងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត ។
- ល្អាងទឹកក្រោមដី គឺទឹកក្រោមដីដែលស្ថិតនៅជាអចិន្ត្រៃយ៍ក្នុងល្អាងធម្មជាតិក្រោមដី ។
- អាងទន្លេ គឺតំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាលនៃប្រព័ន្ធទឹកហូរដោយរាប់បញ្ចូលទាំងទឹកលើដី និងទឹកក្រោមដី ។
- អាងទន្លេរង គឺផ្នែកមួយនៃអាងទន្លេ ។
- ទន្លេអន្តរជាតិ គឺទន្លេដែលមានភូមិសាស្ត្រពាក់ព័ន្ធដល់ទឹកដីប្រទេសចាប់ពីពីរឡើងទៅ ។
- ច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក គឺចំណែកដីដែលធម្មតាលិចដោយទឹកនៅក្នុងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក ដោយរាប់បញ្ចូលទាំងដី ថ្ម ឬអង្គធាតុដទៃទៀតដែលជាប់នៅនឹងច្រាំងនោះ ដោយមិនរាប់បញ្ចូលនូវដី ថ្ម ឬ អង្គធាតុដទៃទៀតដែលនៅឆ្ងាយពីច្រាំង និងលិចទឹកម្តងម្កាលនោះទេ ។
- ឆ្នេរ សមុទ្រ ទន្លេ ស្ទឹង គឺចំណែកដី ឬខ្សាច់ដែលមានសណ្ឋានជម្រាល និងលិចទឹកម្តងម្កាល ។
- បាតទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក គឺផ្នែកមួយនៃដីដែលកំណត់ដោយច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹកដែលគ្របដណ្តប់ដោយទឹក ។
- តម្រូវការសាធារណៈ គឺការផ្គត់ផ្គង់ទឹកនៅតាមទីក្រុង និងជនបទ ការផលិតស្បៀង ការផលិតថាមពលវារីអគ្គិសនី ការបំរើវិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យនាវាចរ និងការរក្សាឱ្យមានធារទឹកអប្បបរមាដើម្បីថែរក្សា បរិស្ថាន ជីវិតមនុស្ស ជីវិតមច្ឆជាតិ និងរុក្ខជាតិនានា ។
- ការងារទឹក គឺសំណង់ទំនប់ធំ តូច ទំនប់បង្វែរ ទំនប់បញ្ចូលទឹក ទំនប់ការពារទឹកជំនន់ ប្រឡាយដោះទឹកធំ តូច ប្រព័ន្ធស្រោចស្រព អាងទឹកធំតូច ប្រឡាយនាំទឹក អណ្តូងទឹកគ្រប់ប្រភេទ **ទំនប់វារីអគ្គិសនី** និងសំណង់ដទៃទៀត ដែលបានសាងសង់ក្នុងគោលបំណងបង្វែរទឹក រក្សាទឹកទុក នាំទឹកយកទឹកប្រើប្រាស់ អភិរក្សការពារធនធានទឹក ដោះទឹកចេញពីតំបន់ដីលិចទឹក ការពារកាត់បន្ថយនូវឥទ្ធិពលទឹកជំនន់ និងសង្គ្រោះបន្ទាន់ផ្សេងៗទៀតដែលពាក់ព័ន្ធនឹងទឹក ។
- អាជ្ញាប័ណ្ណទឹក គឺប័ណ្ណដែលផ្តល់សិទ្ធិប្រើប្រាស់ទឹក និងធនធានទឹកឱ្យដល់បុគ្គលគ្រប់រូបដើម្បីធ្វើអាជីវកម្ម និង អភិវឌ្ឍ ។
- បុគ្គល គឺរូបវន្តបុគ្គល ឬនិតិបុគ្គល ទោះក្នុងន័យជាឯកជន ឬសាធារណៈក៏ដោយ ។

- **មាត្រា ៣** : ទឹក និងធនធានទឹក ជាសម្បត្តិរបស់រដ្ឋ ។
- **មាត្រា ១១** : បុគ្គលគ្រប់រូបមានសិទ្ធិប្រើប្រាស់ធនធានទឹកក្នុងបរិមាណមួយ មិនលើសពីសេចក្តីត្រូវការចាំបាច់ជាមូលដ្ឋានសំរាប់ការ ហូបចុក ពោកគក់ ងូត និងតម្រូវការផ្សេងទៀត រួមមានការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការស្រោចស្រពសួនច្បារ និងដំណាំ ដោយ ចៀសវាងមិនឱ្យមានការប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់អ្នកដទៃ ។ តម្រូវការខាងលើនេះ មិនតម្រូវឱ្យសុំអាជ្ញាប័ណ្ណទឹកឡើយ ។

- **មាត្រា ១២** : ការបង្វែរទឹក ការយកទឹក ការប្រើប្រាស់ធនធានទឹក ក្នុងគោលបំណងកសិកម្ម ឬឧស្សាហកម្ម លើសពីកំរិតដែលមាន ចែងក្នុងមាត្រា ១១ និងសំណង់ការងារទឹកដែលពាក់ព័ន្ធ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬលិខិតអនុញ្ញាត ។

  បែបបទនៃការសុំនេះ នឹងមានចែងនៅក្នុងអនុក្រឹត្យ ។

  ការយកខ្សាច់ ដី ឬក្រួស ប្រេងកាត និងឧស្ម័នពីបាតច្រាំង ឆ្នេរសមុទ្រ ឆ្នេរទន្លេ ស្ទឹង ព្រែក អូរ បឹងបួរ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ។ បែបបទបច្ចេកទេសជលសាស្ត្រដែលពាក់ព័ន្ធនឹងការងារនេះ នឹងមានចែងលំអិតនៅក្នុងអនុក្រឹត្យ ។

  ការលុបទន្លេ ស្ទឹង ព្រែក អូរ បឹងបួរ ប្រឡាយ អាងទឹក និងអាងធម្មជាតិ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬលិខិតអនុញ្ញាតិ ។ បែបបទនៃការសុំនេះ នឹងមានចែងនៅក្នុងអនុក្រឹត្យ ។

  ការសាងសង់ស្ពានតូច ធំកាត់ទន្លេ ស្ទឹង កំពង់ផែ ឬសំណង់អគារតូច ធំលើច្រាំង និងឆ្នេរ តម្រូវឱ្យមានការឯកភាពផ្នែកបច្ចេកទេសជលសាស្ត្រជាមុន ពីក្រសួងធនធានទឹក និងឧតុនិយម ។

  ការបង្វែរទឹកពីប្រភពដើមចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការអនុញ្ញាត និងយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា ដោយមានការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ ។

- **មាត្រា ១៤** : មុនពេលផ្តល់អាជ្ញាប័ណ្ណទឹកដល់បុគ្គលណាមួយ ក្រសួងធនធានទឹក និងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានលើការប្រើប្រាស់ទឹក និងការសាងសង់សំណង់ការងារទឹកដែលបុគ្គលនោះស្នើឡើង ។

Draft

- **មាត្រា ២២** : រាល់ការបញ្ចេញចោល ការទុកចោល ឬការរក្សាទុកនូវសារធាតុពុលដែលអាចធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹក និងអាច បង្កគ្រោះថ្នាក់ដល់មនុស្ស សត្វ និងរុក្ខជាតិ ត្រូវតែសុំអាជ្ញាប័ណ្ណទឹក ឬការអនុញ្ញាត ។

  ប្រភេទសារធាតុពុលដែលមានចែងខាងលើ និងស្តង់ដាបច្ចេកទេសនៃការបញ្ចេញទឹកសំណល់នឹងមានកំណត់ដោយអនុក្រឹត្យ ។

  រាល់កិច្ចដំណើរការក្នុងមាត្រានេះ ក្រសួងធនធានទឹក និងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធនានា ។

- **មាត្រា ២៣** : ក្រសួងធនធានទឹក និងឧតុនិយម អាចប្រកាសទុកជាតំបន់អាសន្ន ឬជាតំបន់ហាមឃាត់ការប្រើប្រាស់ទឹក ក្នុងករណីដែល :

  - ទឹកលើដី ឬទឹកក្រោមដីត្រូវបានប៉ះពាល់ផ្នែកបរិមាណ គុណភាព ឬតុល្យភាពអេកូឡូស៊ី
  - ទឹកលើទីជំរាលដែលកំពុងរងការគំរាមកំហែងដោយសកម្មភាពមនុស្ស ឬធម្មជាតិ
  - ទឹកដែលបណ្តាលឱ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ ។

ដែនភូមិសាស្ត្រនៃតំបន់អាសន្ន ឬតំបន់ហាមឃាត់នោះ ត្រូវកំណត់តាមករណីនីមួយៗ ដោយប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម ។

- **មាត្រា ៣២** : រាល់វិវាទដែលពាក់ព័ន្ធការបង្កើត និងដំណើរការសេវាភាពក្នុងការប្រើប្រាស់ទឹកត្រូវសម្រួលដោះស្រាយដោយក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

- **មាត្រា ៣៥** : រាជរដ្ឋាភិបាលអាចផ្តល់រង្វាន់លើកទឹកចិត្ត ឬភាពអនុគ្រោះផ្សេងៗដល់បុគ្គលទាំងឡាយដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវ ការបង្កើតបច្ចេកវិទ្យាថ្មីៗ ឬការដំឡើងឧបករណ៍ទំនើបដែលជួយកាត់បន្ថយកាកសំណល់ និងជួយបង្កើនគុណភាពទឹក ដើម្បីឱ្យការប្រើប្រាស់ទឹកមានប្រសិទ្ធិភាពខ្ពស់ ។
លក្ខណៈវិនិច្ឆ័យ និង បែបបទសំរាប់ការផ្តល់រង្វាន់លើកទឹកចិត្ត ឬភាពអនុគ្រោះផ្សេងៗត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម ។

- **មាត្រា ៣៦** : បទល្មើសនឹងបញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មដូចតទៅ :

១- ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីពីរយពាន់ (២០០.០០០) រៀល ដល់ពីរលាន (២.០០០.០០០)រៀល ចំពោះបុគ្គលណាដែល :

- រំលោភលើលក្ខខ័ណ្ឌនានាដែលមានកំណត់ក្នុងអាជ្ញាប័ណ្ណទឹក ។
- រារាំងដោយគ្មានមូលហេតុត្រឹមត្រូវ មិនឱ្យមន្ត្រីមានសមត្ថកិច្ចបំពេញនូវតួនាទីរបស់ខ្លួន ។
- សង់សំណង់ធារាសាស្ត្រដោយគ្មានអាជ្ញាប័ណ្ណទឹក ។

២- ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីពីរលាន (២.០០០.០០០) រៀល ដល់ប្រាំលាន (៥.០០០.០០០) រៀល និងឬដាក់ពន្ធនាគារពីមួយ (១) ខែ ដល់ប្រាំមួយ (៦) ខែ ចំពោះបុគ្គលណា :

- ប្រើប្រាស់ទឹកដោយគ្មានសុំអាជ្ញាប័ណ្ណទឹក ឬ លិខិតអនុញ្ញាត ក្នុងករណីដែលច្បាប់តម្រូវឱ្យមាន ។
- ជីក ឬខួងអណ្តូងយកទឹកក្រោមដីធ្វើអាជីវកម្ម ដោយគ្មានអាជ្ញាប័ណ្ណទឹក ។ ប្រាក់ពិន័យនេះនឹងឡើងទ្វេរដងកាលណាការជីក ឬខួងអណ្តូងបណ្តាលឱ្យមានការស្រុត ឬបាក់ដី ។ ជនល្មើសត្រូវទទួលខុសត្រូវចំពោះការខូចខាត ដែលបណ្តាលមកពីការស្រុត ឬបាក់ដីនេះ ។

៣- ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ដល់ដប់លាន (១០.០០០.០០០) រៀល និងឬដាក់ពន្ធនាគារពីមួយ (១) ឆ្នាំ ដល់ប្រាំ (៥) ឆ្នាំ ចំពោះបុគ្គលណា :

- លុបបឹងធម្មជាតិ ស្រះ ត្រពាំង និងអាងទឹកដោយគ្មានលិខិតអនុញ្ញាត ។
- បង្ហូរចោលទឹកសំណល់ដែលមានជាតិពុលចូលក្នុងប្រភពទឹកដោយគ្មានអាជ្ញាប័ណ្ណទឹក ។
- ធ្វើសកម្មភាពបំពាននៅក្នុងតំបន់ហាមឃាត់ ។
- បង្កឧបសគ្គ ឬធ្វើឱ្យរាំងស្ទះដល់លំហូរធម្មជាតិនៃទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ ដោយគ្មានការអនុញ្ញាត ។
- ធ្វើអាជីវកម្មខ្សាច់ ដី ថ្ម និងក្រួសពីបាតទន្លេ ស្ទឹង ព្រែក និងច្រាំងដោយគ្មានអាជ្ញាប័ណ្ណទឹក ។

៤- គ្រប់ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេរមួយជាពីរ ។

- **មាត្រា ៣៧** : បុគ្គលណាដែលបង្កឱ្យមានការខូចខាតដល់សំណង់ការងារទឹកសាធារណៈ នឹងត្រូវទទួលការផ្តន្ទាទោសទៅក្រមព្រហ្មទណ្ឌ ជាធរមាន ។

Draft

- **មាត្រា ៣៩** : បន្ថែមលើទោសប្បញ្ញត្តិដូចមានចែងក្នុងមាត្រាខាងលើ ជនល្មើសត្រូវរុះរើចេញនូវប្រភេទសំណង់ដែលខ្លួនបានសាងសង់ និងរៀបចំជួសជុលទីកន្លែងឱ្យបានដូចស្ថានភាពដើមវិញ ហើយឧបករណ៍ គ្រឿងចក្រដែលពាក់ព័ន្ធនឹងបទល្មើស ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។
- **មាត្រា ៤០** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

## ៣.៧ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ ២០០៧

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៧ និតិកាលទី ៣ ។

*មាត្រា ១:* ច្បាប់នេះកំណត់ក្របខណ្ឌនៃការគ្រប់គ្រងការអភិរក្សនិងការអភិវឌ្ឍតំបន់ការពារធម្មជាតិ ។ គោលបំណងនៃច្បាប់នេះគឺធានានូវការគ្រប់គ្រង ការអភិរក្សជីវៈចម្រុះនិងការធានាប្រើប្រាស់ធនធានធម្មជាតិប្រកប ដោយ និរន្តរភាព ។

*មាត្រា ២:* ច្បាប់នេះ មានវិសាលភាពអនុវត្តនៅតំបន់ការពារធម្មជាតិ ដែលកំណត់ដោយបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រង ធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស. រកម.១២៩៦-៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើត និងការកំណត់តំបន់ ការពារធម្មជាតិ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ព្រះរាជក្រឹត្យស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ជីវមណ្ឌលបឹងទន្លេសាបលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០០១ និងលិខិតបទដ្ឋានច្បាប់ផ្សេងទៀត ។

*មាត្រា ៤:* ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដូចមានចែងនៅក្នុងមាត្រា២ នៃច្បាប់នេះត្រង់ស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថានមានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិជាសេនាធិការសំរាប់គ្រប់គ្រង តំបន់ការពារធម្មជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។ ការរៀបចំ និងការប្រព្រឹត្តទៅ របស់រដ្ឋបាលការពារ និងអភិរក្សធម្មជាតិក្នុងតំបន់ការពារធម្មជាតិនីមួយៗ ត្រូវកំណត់ដោយប្រកាស របស់ក្រសួងបរិស្ថាន ។ ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ត្រូវធានានូវសិទ្ធិរបស់សហគមន៍ មូលដ្ឋានជនជាតិដើមភាគតិច និង សាធារជន ដើម្បីចូលរួមក្នុងការធ្វើសេចក្តីសំរេចចិត្តលើការគ្រប់គ្រង និងការអភិរក្សជីវៈចម្រុះប្រកបដោយ និរន្តរភាព ។

*មាត្រា ៦:* មន្ត្រីរដ្ឋបាលការពារនិងអភិរក្សធម្មជាតិមានសិទ្ធ និងភារកិច្ចសំខាន់ៗ ដូចខាងក្រោម :

១-យាមល្បាត ត្រួតពិនិត្យជាប្រចាំ ទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិគ្រប់ប្រភេទនៅក្នុងតំបន់ ការពារធម្មជាតិ ។

២-ត្រួតពិនិត្យលិខិតអនុញ្ញាត និងឯកសារផ្សេងៗដែលកំណត់ដោយច្បាប់នេះ

៣-មានវិធានការទប់ស្កាត់ភ្លើងឆេះព្រៃ ក្នុងតំបន់ការពារធម្មជាតិ

៤-ត្រួតពិនិត្យរាល់ការនាំចេញ ការនាំចូលនូវប្រភេទសត្វ រុក្ខជាតិ គ្រាប់រុក្ខជាតិ និងសំណាក ក្នុងតំបន់ការពារ ធម្មជាតិ

៥-ធ្វើការអប់រំផ្សព្វផ្សាយ និងសម្របសម្រួល ជាមួយសហគមន៍មូលដ្ឋានជនជាតិដើមភាគតិចក្នុងដំណើរការរៀបចំ និងការអនុវត្តរបស់សហគមន៍តំបន់ការពារធម្មជាតិ ។ សិទ្ធ និងភារកិច្ចលំអិតរបស់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

Draft

មាត្រា ៨: ការសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិណាមួយត្រូវផ្អែកតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវលក្ខណៈវិនិច្ឆ័យ គោលបំណងនៃការគ្រប់គ្រង សិទ្ធប្រើប្រាស់ធនធានធម្មជាតិ សិទ្ធិកាន់កាប់ដីធ្លី និងកត្តាពាក់ព័ន្ធផ្សេងទៀត។ ការស្នើសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិណាមួយ ត្រូវភ្ជាប់មកជាមួយនូវ:

១-ការអធិប្បាយអំពីសារៈសំខាន់ខាងផ្នែកជីវៈចម្រុះ សណ្ឋានដី ភូគព្ភសាស្ត្រ ប្រវត្តិសាស្ត្រ វប្បធម៌ និងការអភិរក្សតំបន់ដែលស្នើសុំរៀបចំប្រែតំបន់ការពារធម្មជាតិនោះ

២-ការអធិប្បាយអំពីលក្ខណៈច្បាប់ នៃតំបន់ដែលស្នើសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិ ភ្ជាប់ជាមួយនូវផែនទីមានមាត្រដ្ឋានកំណត់ច្បាស់លាស់ ដែលបង្ហាញយ៉ាងច្បាស់អំពី ទីតាំង ព្រំប្រទល់ និងទំហំនៃតំបន់ការពារធម្មជាតិនោះ

៣-ការបញ្ជាក់ពីគោលបំណង នៃការគ្រប់គ្រងតំបន់ស្នើរៀបចំ និងការគម្រោងកំហែងចំពោះមុខ

៤-ការសិក្សាលើការប្រើប្រាស់ធនធានធម្មជាតិ និងដីធ្លី នៅក្នុងតំបន់ការពារធម្មជាតិ

៥-របាយការណ៍អំពីលទ្ធផលនៃការពិគ្រោះយោបល់ ជាមួយស្ថាប័ន ភាគីពាក់ព័ន្ធ និងតំណាងអាជ្ញាធរមូលដ្ឋានដែលមានទីតាំងនៅក្នុង ឬ ក្បែរតំបន់ស្នើសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិ។ ការរៀបចំកែប្រែតំបន់ការពារធម្មជាតិណាមួយ ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា ២២: រដ្ឋទទួលស្គាល់ និងធានាសិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណី ទំនៀមទំម្លាប់ជំនឿសាសនារបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលរស់នៅក្នុងតំបន់ការពារធម្មជាតិ។ សិទ្ធិប្រើប្រាស់ធនធានធម្មជាតិជា លក្ខណៈប្រពៃណី ទំនៀមទម្លាប់ តាមតម្រូវការរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ជាលក្ខណៈគ្រួសារ អាចប្រព្រឹត្តទៅបាននៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់អភិរក្ស ដោយអនុវត្ត ទៅតាមគោលការណ៍ណែនាំ ដែលកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

មាត្រា ៣៦: ការកាប់គាស់ ការឈូសឆាយដីព្រៃក្នុងតំបន់ការពារធម្មជាតិ ដើម្បីស្ថាបនាអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈគ្រប់ប្រភេទ ដែលកាត់តាមតំបន់ស្នូល និងតំបន់អភិរក្សត្រូវហាមឃាត់។ ករណីនេះអាចធ្វើទៅបានតែក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ដោយមានការសម្រេចពីរដ្ឋាភិបាលតាមការស្នើរបស់ក្រសួងបរិស្ថាន។

មាត្រា ៣៩: រាល់ការនាំចេញ ការនាំចូល ឬ ការដោះដូរ ដែលពុំមានលក្ខណៈពាណិជ្ជកម្ម នូវប្រភេទសត្វ រុក្ខជាតិគ្រាប់រុក្ខជាតិ ការបង្កាត់ពូជ និងសំណាករបស់ប្រភេទទាំងនោះដែលមានដើមកំណើតនៅក្នុងតំបន់ការពារធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា ជាមួយប្រទេសដទៃ ត្រូវធ្វើការសិក្សាស្រាវជ្រាវ វិភាគវិនិច្ឆ័យ និងវាយតម្លៃឱ្យបានច្បាស់លាស់ពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនិងត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន។

មាត្រា ៤០: ហាមបង្កឱ្យភ្លើងឆេះព្រៃក្នុងតំបន់ការពារធម្មជាតិ។ ការប្រើប្រាស់ភ្លើងអាចអនុគ្រោះបានចំពោះរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដើម្បីផលប្រយោជន៍រុក្ខវប្បកម្ម ផ្លូវភ្លើង ឬ អនាម័យព្រៃ។ ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់មានកាតព្វកិច្ចចូលរួមសហការក្នុងការថែរក្សា ការពារព្រៃឈើក្នុងការប្រយុទ្ធទប់ស្កាត់ភ្លើងឆេះព្រៃ។

Draft

មាត្រា ៤១៖ តំបន់ការពារធម្មជាតិនីមួយៗ ត្រូវការពារ និងទប់ស្កាត់នូវរាល់សកម្មភាព ដែលធ្វើឱ្យខូចខាត ឬ ប៉ះពាល់អវិជ្ជមានក្នុងតំបន់ការពារធម្មជាតិ បណ្តាលមកពីការកាប់គាស់រុករាន ទន្ទ្រានដីព្រៃដោយរំលោភ ការធ្វើអាជីវកម្ម ការបំពុលមជ្ឈដ្ឋានធនធានជីវៈចម្រុះ ភ្លើងឆេះព្រៃ ការធ្វើកសិកម្មពនេចរ ការនាំចូលជម្ងឺសត្វល្អិតចង្រៃ និងប្រភេទរុក្ខជាតិ ឬសត្វរាតត្បាត។

សកម្មភាពដែលនាំឱ្យខូចខាត ឬ ប៉ះពាល់អវិជ្ជមាន ដែលត្រូវហាមឃាត់ក្នុងតំបន់ការពារធម្មជាតិមាន:

១-រំកិល ដកចេញ ឬ បំផ្លាញគោលសីមា ឬ សញ្ញាសម្គាល់ព្រំប្រទល់តំបន់ការពារធម្មជាតិ

២-ប្រើសិទ្ធិប្រើប្រាស់ធនធានធម្មជាតិខុសពី សិទ្ធិដែលបានទទួលស្គាល់ ឬ បានអនុញ្ញាតដោយច្បាប់

៣-កាប់ ផ្តួល រំលំ គ្រៀវ កាប់បំផ្លាញដើមឈើ ឬ បំពុល ឬ គាស់រម្លើងគល់ឈើ

៤-ការចាប់ ប្រមាញ់ ប្រមូលពង កូនសត្វព្រៃ និងសត្វស្លាប តាមគ្រប់រូបភាព

៥-ការបំផ្លាញគុណភាពទឹកតាមគ្រប់រូបភាព ការដាក់ថ្នាំបំពុល ការប្រើសារធាតុគីមី ការចោលសំណល់រឹងរាវចូលក្នុងទឹក ឬ លើដី ការប្រើប្រាស់ឧបករណ៍ឆក់

៦-ការស្តុក ការទិញ និងការតាំងលក់សត្វព្រៃ សំណាកសត្វព្រៃគ្រប់ប្រភេទ

៧-ការបំផ្លាញវាលស្មៅធម្មជាតិ រុក្ខជាតិនានា និងទីជម្រកសត្វព្រៃ

៨-ការលែងសត្វពាហនៈ និងបណ្តើរឆ្កែប្រមាញ់

៩-ការនេសាទដែលផ្ទុយនឹង បទប្បញ្ញត្តិនៃច្បាប់ការធ្វើឱ្យប៉ះពាល់ដល់ធនធានធម្មជាតិ ទាំងក្នុងដែនសមុទ្រ និងដែនទឹកសាបព្រៃលិចទឹកព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រ

១០-ការបង្កើតមូលដ្ឋាននិងកែច្នៃខ្លឹមច័ន្ទន៍ ដើមម្រះព្រៅ វល្លិរមៀត ឬអនុផលព្រៃឈើផ្សេងទៀត និងការធ្វើវារីវប្បកម្មទឹកសាប ទឹកប្រៃ ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់និងបច្ចេកទេសដែលនាំដល់ការបំពុល ឬ បំផ្លាញមជ្ឈដ្ឋានជីវៈចម្រុះ និង ប្រព័ន្ធអេកូឡូស៊ី។

មាត្រា ៤២៖ ហាមឃាត់ការកែច្នៃផលអនុផលធនធានធម្មជាតិ ការបង្កើត និងដំណើរការមូលដ្ឋានរោងអារ ជ្រៀកឈើ រោងចក្រកែច្នៃឈើសិប្បកម្មកែច្នៃផល អនុផលធនធានធម្មជាតិ និងឡគ្រប់ប្រភេទ ក្នុងតំបន់ការពារធម្មជាតិ។

មាត្រា ៤៤៖ ដើម្បីកាត់បន្ថយជាអតិបរមានូវហេតុប៉ះពាល់បរិស្ថាន និងសង្គម និងសម្រេចឱ្យបាននូវគោលបំណងយុទ្ធសាស្ត្រ នៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ រាល់គម្រោងអភិវឌ្ឍ ឬវិនិយោគក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ក្រសួងបរិស្ថានត្រូវធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមជាមុនដោយសហការ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។ នីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមសម្រាប់គម្រោង ឬសកម្មភាព ណាមួយត្រូវអនុលោមតាមបទប្បញ្ញត្តិទាំងឡាយ ដែលពាក់ព័ន្ធនឹងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង សង្គម។

មាត្រា ៤៥៖ បទល្មើសធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ ជាបទល្មើសព្រហ្មទណ្ឌដែលមានចរិតពិសេសដូចបានចែងក្នុងច្បាប់នេះ។ មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ បំពេញភារកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ និងជាភ្នាក់ងារនគរបាលយុត្តិធម៌ មានសមត្ថកិច្ចស៊ើបអង្កេត ស្រាវជ្រាវ បង្ក្រាប ទប់ស្កាត់បទល្មើសធនធានធម្មជាតិនៅក្នុងរង្វង់ដែនសមត្ថកិច្ចរបស់ខ្លួន និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ។ ប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ក្នុងតំបន់

Draft

ការពារធម្មជាតិដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងជាភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។ បន្ទាប់ពីសាលក្រម ឬ សាលដីកាចូលជាស្ថាពរ វត្ថុតាង ដែលបានរឹបអូសទុកជាសម្បត្តិរដ្ឋត្រូវចាត់ចែងតាមនីតិវិធីដោយរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន។

មាត្រា ៥៤: មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិដែលមានសមត្ថកិច្ចមានសិទ្ធិផ្អាកសកម្មភាពទាំងមូល ឬ មួយផ្នែកជាបណ្តោះអាសន្នរបស់បុគ្គលណាដែលប្រព្រឹត្តល្មើស និងបទប្បញ្ញត្តិនៃច្បាប់នេះ ឬ បំពានលើកិច្ចសន្យារហូតដល់ដំណោះស្រាយនៃវិវាទត្រូវបានបញ្ចប់។

មាត្រា ៥៣: ទណ្ឌកម្ម នៃបទល្មើសធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិមាន ទោសដាក់ពន្ធនាគារ ទោសពិន័យដោយតុលាការ ពិន័យអន្តរការណ៍ រឹបអូសវត្ថុតាង ជួសជុលស្តារការខូចខាត ព្រមាន ព្យួរដកហូតលិខិតអនុញ្ញាត ឬលុបកិច្ចសន្យា។ ការព្យួរ ការដកហូតលិខិតអនុញ្ញាត ឬ ការលុបកិច្ចសន្យា ជាសិទ្ធិរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។ ការពិន័យអន្តរការណ៍លើបទល្មើសធនធានធម្មជាតិការជួសជុលស្តារការខូចខាតនិងការព្រមានជាសមត្ថកិច្ចរបស់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ។ ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ឬ ធ្វើការជួសជុលស្តារការខូចខាត មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ត្រូវកសាងសំណុំរឿងបទល្មើសបញ្ជូនទៅតុលាការ។ ការរឹបអូសវត្ថុតាង ជាសមត្ថកិច្ចរបស់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ឬ តុលាការ អាស្រ័យទៅតាមករណីនីមួយៗ ដែលបានកំណត់ក្នុងច្បាប់នេះ។

មាត្រា ៦០: ត្រូវផ្តន្ទាទោសជាបទល្មើសធនធានធម្មជាតិថ្នាក់ទី ២ និងត្រូវរឹបអូសវត្ថុតាងជាសម្បត្តិរដ្ឋចំពោះជនដែលបានប្រព្រឹត្តបទល្មើសណាមួយ ដូចខាងក្រោម:

១-ប្រើប្រាស់សារធាតុពុលគ្រប់ប្រភេទដែលធ្វើឱ្យប៉ះពាល់ដល់ធនធានធម្មជាតិ

២-ធ្វេសប្រហែសបង្កឱ្យមានភ្លើងឆេះព្រៃ

៣-យាយី បំផ្លាញជម្រកពង កូនកន្លែងបន្តពូជសត្វព្រៃ និងមច្ឆជាតិ .

៤-កាប់បំផ្លាញរុក្ខជាតិក្នុងតំបន់ស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញ

៥-ប្រើប្រាស់ឧបករណ៍នានា ដែលបង្កការរំខានដោយសម្លេង រំញ័រ រលក និង ផ្សែង

៦-លាក់បាំង ធ្វើឱ្យបាត់បង់ ឬធ្វើឱ្យខូចខាតវត្ថុតាងនៃបទល្មើស

៧-ប្រមូលផ្លែឈើព្រៃ តាមវិធីកាប់រំលំដើម

៨-កម្ទេច ផ្លាស់ប្តូរ លុបបំបាត់ ឬ ធ្វើឱ្យខូចខាតផ្លាកសញ្ញាគ្រប់ប្រភេទ

៩-បោះបង្គោលហ៊ុមព័ទ្ធ ដាក់សញ្ញាសម្គាល់ ក្នុងគោលបំណងកាន់កាប់ជាកម្មសិទ្ធ។ ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង។

មាត្រា ៦១: ត្រូវផ្តន្ទាទោស ជាបទល្មើសធនធានធម្មជាតិថ្នាក់ទី ៣ និងរឹបអូសវត្ថុតាងជាសម្បត្តិរដ្ឋ ចំពោះជនដែលបានប្រព្រឹត្តបទល្មើសណាមួយ ដូចខាងក្រោម÷

១-ធ្វើឱ្យខូចខាត ឬ ប្រែប្រួលសភាពដើម រំកិល ឬបង្ខិតបង្គោលព្រំប្រទល់ និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ

២-ការបង្កើតមូលដ្ឋានកែច្នៃផល អនុផលធនធានធម្មជាតិគ្រប់ប្រភេទ

៣-កែច្នៃខ្លឹមច័ន្ទន៍ ម្រះព្រៅ វល្លិរមៀត និងចម្រាញ់រុក្ខជាតិផ្សេងទៀត

៤-កាប់ គ្រៀវ ចង រឹត គាស់រម្លើង កាប់រំលំ ប្រមូល បំផ្លាញ រុករាន និងធ្វើសន្និធិរុក្ខជាតិដែលរងគ្រោះថ្នាក់ ឬ មានដោយកម្រ និងជិតផុតពូជដែលបានកំណត់ដោយប្រកាសក្រសួងបរិស្ថាន

៥-ចាប់ដោយដាប់អន្ទាក់ ខ្នារ អង្គប់ បន្ទឹង លប់ ដោយបង្កៃ ឬ ដោយប្រមាញ់ដែលធ្វើឱ្យរបួសបំពុល សម្លាប់ នាំចេញ ប្រមូលពង និងកូនសត្វព្រៃ គ្រប់ប្រភេទ ដែលកំពុងរងគ្រោះថ្នាក់មានដោយកម្រ និងជិតផុតពូជ ដែល បានកំណត់ដោយប្រកាសក្រសួងបរិស្ថាន

៦-ប្រើប្រាស់អាវុធជាតិផ្ទុះ ជាតិគីមី ថ្នាំពុល គ្រឿងឆក់ ធ្វើឱ្យខូចខាតដល់ធនធានធម្មជាតិ

៧-រារាំង បង្កគ្រោះថ្នាក់ របួសស្នាម ដល់មន្ត្រីរដ្ឋបាលការពារ និងអភិរក្ស ធម្មជាតិ ក្នុងការចុះអនុវត្តមុខនាទី និងភារកិច្ចរបស់ខ្លួន

៨-ក្លែងបន្លំដោយប្រើប្រាស់ ឯកសណ្ឋាន ផ្លាកសញ្ញាសម្គាល់ ឬ ឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលការពារ និង អភិរក្សធម្មជាតិ ដើម្បីធ្វើសកម្មភាពល្មើស

៩-ក្លែងបន្លំលិខិតបទដ្ឋានរបស់ស្ថាប័នមានសមត្ថកិច្ចដើម្បីធ្វើសកម្មភាពល្មើស

១០-បំផ្លិចបំផ្លាញបង្គោលព្រំប្រទល់ ស្លាក លូ ផ្លូវ អគារ ទីស្នាក់ការ បេដ្ឋារចនាសម្ព័ន្ធសាធារណៈ ។ ក្នុងករណីមិន រាងចាលត្រូវទទួលផ្ទន្ទាទោសទ្វេដង ។

## ៣.៨ អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក ឆ្នាំ ១៩៩៩

អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក បានអនុម័តនៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩៩ ។ អនុក្រឹត្យនេះ :

- មានគោលដៅ កំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹក សាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចំរុះ
- មានវិសាលភាពអនុវត្តចំពោះរាល់ប្រភេទបំពុល និងរាល់សកម្មភាពទាំងឡាយ ដែលបង្កឱ្យមានការបំពុលទឹកនៅ តាមតំបន់ទឹកសាធារណៈ ។
- ឧបសម្ព័ន្ធ១ : ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់
- ឧបសម្ព័ន្ធ២ : កំរិតកំណត់ស្តង់ដានៃការបញ្ចេញសំណល់រាវ ពីប្រភពបំពុលចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬ ទៅក្នុង ប្រព័ន្ធបណ្តាញលូ
- ឧបសម្ព័ន្ធ៣ : ប្រភេទនៃប្រភពបំពុល ដែលតម្រូវឱ្យមានការសុំអនុញ្ញាតិពីក្រសួងបរិស្ថាន មុននឹងបញ្ចេញចោលនូវ សំណល់រាវរបស់ខ្លួន ឬ ដឹកទៅទីផងទៃ
- ឧបសម្ព័ន្ធ៤ : កំរិតកំណត់ស្តង់ដាគុណភាពទឹក នៅតាមតំបន់ទឹកសាធារណៈ សំរាប់អភិរក្សជីវៈចំរុះ នៅក្នុងទឹក
- ឧបសម្ព័ន្ធ៥ : កំរិតកំណត់ស្តង់ដាគុណភាពទឹក នៅតាមតំបន់ទឹកសាធារណៈ សំរាប់ការពារសុខភាពសាធារណៈ ។

Draft

## ៣.៩ អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង ឆ្នាំ ១៩៩៩

អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹង បានអនុម័តនៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩ ។ អនុក្រឹត្យនេះ :

- មានគោលដៅកំណត់ការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និង ប្រកបដោយសុវត្ថិភាព សំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវៈចំរុះ
- មានវិសាលភាពអនុវត្ត ចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោល សំរាម និង សំណល់ប្រកបដោយគ្រោះថ្នាក់ មានភ្ជាប់ជាមួយនូវឧបសម្ព័ន្ធ ដែលកំណត់នូវប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់ ។

## ៣.១០ អនុក្រឹត្យ ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ ១៩៩៩

អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន បានអនុម័តនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៩ ។ អនុក្រឹត្យនេះមានគោលដៅ :

- កំណត់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន លើរាល់គំរោង និងសកម្មភាពរបស់ឯកជន ឬ សាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតំលៃដោយក្រសួងបរិស្ថានមុននឹងដាក់ជូនរាជរដ្ឋាភិបាលសម្រេច
- កំណត់ប្រភេទ និងទំហំគំរោង សកម្មភាពដែលបានស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និង កំពុងដំណើរការ ទាំងឯកជន ទាំងសាធារណៈ ដែលត្រូវវាយតំលៃហេតុប៉ះពាល់បរិស្ថាន
- បំផុសឱ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណាក្នុងកិច្ចដំណើរការអនុម័តគំរោង ។

## ៣.១១ អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ឆ្នាំ ២០០៣

អនុក្រឹត្យលេខ/១៩ អនក្រ.បក ស្តីពីសម្បទានដីសង្គមកិច្ច អនុម័តនៅថ្ងៃទី ១៩ ខែ មីនា ២០០៣ ដោយរាជរដ្ឋាភិបាល ។

- *<u>មាត្រា ១</u> : អនុក្រឹត្យនេះ កំណត់នីតិវិធី លក្ខណៈវិនិច្ឆ័យ និង យន្តការសំរាប់ធ្វើការផ្តល់សម្បទានដីសង្គមកិច្ច ដើម្បីសង់លំនៅដ្ឋាន ឬ/និងដើម្បីធ្វើកសិកម្មជាលក្ខណៈគ្រួសារ ។*
- *<u>មាត្រា ២</u> : ពាក្យទាំងឡាយខាងក្រោមនេះ មានន័យដូចតទៅ :*
  - *សម្បទានដីសង្គមកិច្ចគឺជាយន្តការផ្ទេរដីឯកជនរបស់រដ្ឋតាមផ្លូវច្បាប់សំរាប់គោលបំណងសង្គមកិច្ចដល់ជនក្រីក្រដែលខ្វះខាតដីសំរាប់ សង់លំនៅដ្ឋាន ឬ/និងធ្វើកសិកម្មជាលក្ខណៈគ្រួសារ*
  - *ដីសម្បទានសង្គមកិច្ច គឺជាដីដែលជាកម្មវត្ថុនៃសម្បទានដីសង្គមកិច្ច*
  - *ការធ្វើកសិកម្មជាលក្ខណៈគ្រួសារ សំដៅសកម្មភាពដាំដំណាំឬចិញ្ចឹមសត្វជាលក្ខណៈគ្រួសារដើម្បីបំពេញសេចក្តីត្រូវការជាមូលដ្ឋាន ។*
- *<u>មាត្រា ៣</u> : ដីសម្បទានសង្គមកិច្ច អាចត្រូវផ្តល់ឱ្យសំរាប់គោលដៅសង្គមកិច្ចដោយអនុលោមតាមគោលដៅណាមួយ ឬ គោលដៅច្រើន ដូចមានខាងក្រោមនេះ :*

  *១- ផ្តល់ដី ដល់គ្រួសារក្រីក្រដែលគ្មានទីលំនៅសំរាប់សង់លំនៅដ្ឋាន ។*

  *២- ផ្តល់ដី ដល់គ្រួសារក្រីក្រសំរាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ។*

Draft

៣- ផ្តល់ដី ដល់គ្រួសារដែលត្រូវផ្លាស់ប្តូរទីលំនៅបណ្តាលមកពីការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំរាប់ការតាំងលំនៅដ្ឋានជាថ្មី ។

៤- ផ្តល់ដី ដល់គ្រួសារដែលរងគ្រោះដោយគ្រោះធម្មជាតិ ។

៥- ផ្តល់ដី ដល់គ្រួសារមាតុភូមិនិវត្តន៍ ។

៦- ផ្តល់ដី ដល់យោធិនរំសាយ និងគ្រួសារយុទ្ធជនពលី ពិការ ។

៧- ជួយសម្រួល ដល់ការអភិវឌ្ឍសេដ្ឋកិច្ច ។

៨- ជួយសម្រួល ដល់សម្បទានដីសេដ្ឋកិច្ច ដោយផ្តល់ដីឡូត៍ដល់កម្មករចំការធំៗសំរាប់សង់លំនៅដ្ឋាន ឬ សំរាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ ។

៩- អភិវឌ្ឍតំបន់ដែលពុំទាន់ត្រូវបានអភិវឌ្ឍសមស្រប ។

- <u>មាត្រា ៤</u> : កម្មវិធីសម្បទានដីសង្គមកិច្ចមាន :
  - កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន
  - កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

- <u>មាត្រា ៦</u> : ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ជូនផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន តាមរយៈក្រុមការងារថ្នាក់ស្រុក ខណ្ឌ ទៅគណៈកម្មាធិការប្រើប្រាស់ និង បែងចែកដីថ្នាក់ខេត្ត ក្រុង ដើម្បីសុំការសម្រេចយល់ព្រម ។

គណៈកម្មាធិការប្រើប្រាស់ និង បែងចែកដីថ្នាក់ខេត្ត ក្រុងអាចផ្តល់ការសម្រេចយល់ព្រមលើផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានប្រសិនបើ ផែនការសម្បទានដីសង្គមកិច្ចនោះ ត្រឹមត្រូវតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ដោយអនុក្រឹត្យនេះ និងប្រសិនបើពិនិត្យឃើញថា ដីនោះជាដីឯកជនរបស់រដ្ឋដែលនៅទំនេរហើយសមស្របសំរាប់ផែនការសម្បទានដីសង្គមកិច្ច ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ត្រូវជូនដំណឹង ដល់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិអំពីផែនការនីមួយ ៗ ដែលគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុងបានផ្តល់ការសម្រេចយល់ព្រម ។

គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អាចពិនិត្យកែសម្រួលផែនការ ឬ លុបចោលសេចក្តីសម្រេចយល់ព្រមរបស់គណៈកម្មាធិការប្រើប្រាស់ និង បែងចែកដីថ្នាក់ខេត្ត ក្រុង ក្នុងរយៈពេលហុកសិប (៦០) ថ្ងៃ គិតពីថ្ងៃបានទទួលផែនការសម្បទានដីសង្គមកិច្ចនេះ ប្រសិនបើ:

ក- ផែនការសម្បទានដីសង្គមកិច្ចនោះ មិនស្របនឹងអាទិភាពនៃការប្រើប្រាស់ដីថ្នាក់ជាតិ មានកំហុសបច្ចេកទេស ឬរំលោភបទប្បញ្ញត្តិ ទាំងឡាយនៃអនុក្រឹត្យនេះ ឬច្បាប់ផ្សេងទៀត ។

ខ- ផែនការដែលបានយល់ព្រម មិនស្របនឹងលក្ខខណ្ឌចាំបាច់ នៃកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

បន្ទាប់ពីបានការយល់ព្រម ក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានជំនួយបច្ចេកទេស ពីក្រុមការងារថ្នាក់ស្រុកខណ្ឌ ជាអ្នកអនុវត្តកម្មវិធីសម្បទានដី សង្គមកិច្ចថ្នាក់មូលដ្ឋាន ។ ផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដែលបានទទួលការសម្រេចយល់ព្រមរួចហើយ ត្រូវបើកចំហរជាសាធារណៈ នៅសាលាឃុំ សង្កាត់ពាក់ព័ន្ធនៅគណៈកម្មាធិការ ប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង និង នៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ច ថ្នាក់ជាតិក្នុងអំឡុងពេលម៉ោងធ្វើការ ។